

ក្របខណ្ឌសុចនាកររបាយការណ៍ស្តីពីប្រព័ន្ធស្បៀងនៅកម្ពុជា

ខែមេសា ឆ្នាំ ២០២៦

សារគន្លឹះ

- កម្ពុជាបានក្លាយជាប្រទេសឈានមុខគេក្នុងតំបន់ លើការធ្វើបរិវត្តកម្មប្រព័ន្ធស្បៀង ប៉ុន្តែប្រព័ន្ធតាមដានវឌ្ឍនភាពការងារនៅមានលក្ខណៈដាច់ដោយឡែកពីគ្នា ដែលកំពុងរារាំងដល់ការអនុវត្ត និងធ្វើឲ្យគណនេយ្យភាពចុះខ្សោយ ព្រមទាំងរឹតត្បិតការទទួលបានហិរញ្ញប្បទានអាកាសធាតុ និងហិរញ្ញប្បទានអភិវឌ្ឍន៍នានា។
- ទោះបីជាកម្ពុជាមានប្រព័ន្ធទិន្នន័យជាតិរឹងមាំក៏ដោយ ក៏បញ្ហាប្រឈមនៅតែមានទៅលើការធ្វើសមាហរណកម្ម ការចាត់អាទិភាព ការប្រើប្រាស់ទិន្នន័យប្រកបដោយសក្តិសិទ្ធិភាព និងមានគម្លាតទិន្នន័យសំខាន់ៗនៅក្នុងផ្នែកមួយចំនួន ពិសេសទិន្នន័យទាក់ទងនឹងបរិស្ថានស្បៀងអាហារ ខ្សែច្រវាក់តម្លៃ ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ច និងបានរារាំងកម្ពុជាពីការតភ្ជាប់គ្នារវាងលទ្ធផលចុងក្រោយនៃផលិតកម្ម ទីផ្សារ របបអាហារ និងផលជះទៅលើសុខភាព ហើយស្ថានភាពនេះ បានមើលរំលងទៅលើសារៈប្រយោជន៍នៃការប្រើប្រាស់ទិន្នន័យ ដើម្បីចង្អុលបង្ហាញសម្រាប់ការរៀបចំគោលនយោបាយ ការធ្វើផែនការ និងការបែងចែកធនធាននៅទូទាំងប្រទេស។
- ការតាមដាននៅថ្នាក់ក្រោមជាតិមានសារៈសំខាន់ ជាពិសេសនៅកម្ពុជា ដោយសារតែភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយទៀតទៅលើស្ថានភាពអាហារូបត្ថម្ភ ភាពក្រីក្រ ភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ និងការទទួលបានទីផ្សារសម្រាប់លក់ផលិតផល។
- ការបង្កើតប្រព័ន្ធតាមដានការងារប្រព័ន្ធស្បៀងរួមមួយ ដែលដឹកនាំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) និងតភ្ជាប់ទៅវិទ្យាស្ថានជាតិស្ថិតិ (NIS) នឹងជួយឱ្យមានការវិវត្តបន្ថែមទៀត ពីការងារវាស់វែងទៅជាការប្រើប្រាស់ លទ្ធផលសម្រាប់ការសម្រេចចិត្ត និងដាក់ចេញសកម្មភាពអនុវត្តជាក់ស្តែង។
- ការប្រើប្រាស់អភិក្រមដែលចង្អុលបង្ហាញដោយគោលនយោបាយ និងមានដំណាក់កាលច្បាស់លាស់អាចឲ្យកម្ពុជាដាក់ដំណើរការបានរហ័សនូវក្របខណ្ឌសុចនាករស្នូលសម្រាប់ការងារតាមដាន ពង្រឹងយន្តការគណនេយ្យភាព និងបិទគម្លាតទិន្នន័យសំខាន់ៗ ជាបន្តបន្ទាប់។

Photo: © AltrendoImages/Envato

Food Systems Countdown Initiative

gain Global Alliance for Improved Nutrition

Food and Agriculture Organization of the United Nations

Johns Hopkins University

Cornell CALS College of Agriculture and Life Sciences

Federal Ministry for Economic Cooperation and Development


giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

សេចក្តីផ្តើម

ប្រព័ន្ធស្បៀងនៅកម្ពុជាមានលក្ខណៈផ្តោតសំខាន់ទៅលើផលសរុបនៃផលិតកម្មទាំងមូល ដោយនាំមកជាមួយនូវបញ្ហាប្រឈមដែលនៅតែកើតមានទាក់ទងនឹងការទទួលបានស្បៀង និងលទ្ធផលចុងក្រោយទាក់ទងនឹងអាហារូបត្ថម្ភ។ កម្ពុជាផលិតស្បៀង សំខាន់ៗបានច្រើន និងមានអតិរេកស្បៀងជាពិសេសស្រូវ ដែលផលិតកម្មប្រចាំឆ្នាំមានប្រហែល ១៥,០៩ លានតោន និងមានអតិរេកជាង ៩,១៥លានតោនដែលអាចនាំចេញបាន។ វិស័យកសិកម្មផ្តល់ការងារដល់ប្រជាជនជាង ៣ លាននាក់ និងរួមចំណែកប្រហែល ១៦% នៃផលិតផលក្នុងស្រុកសរុប និងមានការពង្រីកផលិតកម្មបន្តបន្ទាប់លើដំណាំស្រូវ ដំឡូងមី ស្វាយចន្ទី ដំណាំសាកវប្បកម្ម និងនេសាទ[1] [2] ។ ជំរឿនកសិកម្មឆ្នាំ ២០២៣ បានរកឃើញថាមានអ្នកកាន់កាប់ក្នុងផ្នែកកសិកម្មមានចំនួន១,៨៥ លានឯកតា និងគ្របដណ្តប់លើផ្ទៃដី ៣,២ លានហិកតា ដែលស្ថានភាពនេះ អាចឆ្លុះបញ្ចាំងឲ្យឃើញថា មូលដ្ឋានផលិតកម្មកសិកម្មនៅកម្ពុជាមានទំហំតូចៗ និងស្ថិតនៅតាមជនបទ ដូច្នេះមានភាពចាំបាច់ណាស់ដែលត្រូវផ្តោតការយកចិត្តទុកដាក់លើប្រព័ន្ធផលិតកម្មរបស់កសិករខ្នាតតូច [3] ។ ក្នុងឆ្នាំ២០២៤ ដីកសិកម្មបានពង្រីកបន្ថែមទៀត រហូតដល់ ៤,៤៣ លានហិកតា ដោយសារការធ្វើប្រពលវប្បកម្មដំណាំស្រូវ និងការធ្វើពិពិធកម្មទៅលើដំណាំមិនមែនស្រូវផ្សេងទៀត[1]។ កម្ពុជាក៏បានវិនិយោគបន្ថែមលើខ្សែច្រវាក់តម្លៃផងដែរ រួមមានរោងម៉ាស៊ីនកិនស្រូវ ការកែច្នៃគ្រាប់ស្វាយចន្ទី និងវារីវប្បកម្ម។ ទោះយ៉ាងនេះក្តី កត្តារាំងជាប្រព័ន្ធមួយចំនួននៅតែមាន រួមមាន៖ ផលស្រូវប្រហែល ៦៧% ត្រូវបាននាំចេញដោយមិនទាន់កែច្នៃ ដែលធ្វើឲ្យបាត់បងឱកាសក្នុងការចាប់យកតម្លៃបន្ថែម និងប្រាក់ចំណូលពីការនាំចេញ [4] ។ ខណៈដែលការនាំចេញសរុបនៃផលិតផលកសិកម្មសំខាន់ៗកើនដល់ជិត ៤ ពាន់លានដុល្លារអាមេរិកនៅឆ្នាំ ២០២៥ កម្ពុជានៅតែបន្តពឹងផ្អែកលើការនាំចូលអាហារកែច្នៃ និងអាហារដែលមានការបន្ថែមតម្លៃខ្ពស់ ដែលស្ថានភាពនេះសរបញ្ជាក់អំពីអតុល្យភាពពាណិជ្ជកម្មដែលកំពុងបន្តមាននៅក្នុងប្រព័ន្ធស្បៀងនិងកសិកម្ម[5] [6] ។ អ្វីដែលសំខាន់នោះគឺ ភាពតានតឹងក្នុងតំបន់ និងវិបត្តិទាក់ទងនឹងអាកាសធាតុ រួមមានទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលនៅតែបន្តប៉ះពាល់ដល់ផលិតភាពកសិកម្ម ជីវភាពរស់នៅជនបទ និងសន្តិសុខស្បៀង[4] ។ ទិន្នន័យថ្នាក់ជាតិបង្ហាញថា កុមារអាយុក្រោម ៥ ឆ្នាំ ចំនួន ២២% មានបញ្ហាក្រិសក្រិន និងកុមារប្រហែល ១០% មានបញ្ហាស្គមស្គាំង ខណៈដែលគ្រួសារប្រហែល ១៦% មិនអាច

មូលបទ និងក្រុមសូចនាករក្របខណ្ឌតាមជាន់ស្តីពីប្រព័ន្ធស្បៀង

(ប្រអប់នៅខាងក្រៅសំដៅទៅលើមូលបទដែលពាក់ព័ន្ធវិស័យចម្រុះ ចំណែករង្វង់ខាងក្នុងសំដៅទៅលើលទ្ធផលចុងក្រោយរយៈពេលវែង)



1 National Institute of Statistics. (2024). Cambodia Agriculture Survey 2024. Phnom Penh: National Institute of Statistics.

2 Ministry of Agriculture, Forestry and Fisheries (2026) Annual Report for Agriculture, Forestry and Fisheries Sector for 2025. Phnom Penh: Ministry of Agriculture, Forestry and Fisheries.

3 National Institute of Statistics. (2023). Cambodia Agriculture Census 2023. Phnom Penh: National Institute of Statistics.

4 Food and Agriculture Organization of the United Nations. (2023). Hand-in-Hand Initiative: Cambodia Country Profile. Rome: Food and Agriculture Organization.

5 Ministry of Agriculture, Forestry and Fisheries. (2025). Agricultural Trade and Production Statistics. Phnom Penh: Ministry of Agriculture, Forestry and Fisheries.

6 Open Development Cambodia. (2024). Agricultural Production and Trade Data. Phnom Penh.

មានលទ្ធភាពទទួលបានរបបអាហារដែលមានជីវជាតិ ដែលការណ៍នេះ បានឆ្លុះបញ្ចាំងអំពីវិសមភាពដែលបន្តកើតមាននៅក្នុងការទទួលបានអាហារចម្រុះ និងមានសុខភាពល្អ[7] [8] ។ កម្ពុជាកំពុងជួបប្រទះបន្ទុកបីផ្នែកគ្នានៃបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ គឺការបន្តកើតមាននូវកង្វះអាហារូបត្ថម្ភ និងកង្វះមីក្រូសារធាតុចិញ្ចឹម រួមជាមួយនឹងការកើនឡើងនៃបញ្ហាលើសទម្ងន់ និងធាត់ជ្រុល និងជំងឺមិនឆ្លងដែលទាក់ទងនឹងការផ្លាស់ប្តូរបរិយាកាសនៃការបរិភោគអាហារ។

កម្ពុជាបានឈានចូលដល់ដំណាក់កាលដ៏សំខាន់មួយនៃការធ្វើបរិវត្តកម្មប្រព័ន្ធស្បៀង។ ទិដ្ឋភាពរួមនៃការងារតាមដានវឌ្ឍនភាពប្រព័ន្ធស្បៀងនៅកម្ពុជាមានលក្ខណៈពហុវិស័យ វិមជ្ឈការ និងកំពុងវិវត្តបន្ថែមទៀត។ កម្ពុជាសម្រេចបាននូវវឌ្ឍនភាពសំខាន់ៗក្នុងការកសាងប្រព័ន្ធគ្រប់គ្រងព័ត៌មានជាតិ រួមមានការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (CSES) ការធ្វើអង្កេតកសិកម្មកម្ពុជា (CAS) និងមានប្រព័ន្ធរដ្ឋបាលជាក់លាក់នៅតាមក្រសួងស្ថាប័ននានា។ ទោះយ៉ាងនេះក្តី ការតាមដាននៅតែមានលក្ខណៈបែកខ្ញែកទៅតាមវិស័យ និងតាមក្រសួងស្ថាប័ន។ ភាពបែកខ្ញែកនេះ រារាំងដល់ការវិភាគដែលមានលក្ខណៈរួមបញ្ចូលគ្នាមួយដែលត្រូវការចាំបាច់សម្រាប់ពិនិត្យមើលអំពីបរិវត្តកម្មប្រព័ន្ធស្បៀង រួមមាន ការពិនិត្យមើលទៅលើទំនាក់ទំនងរវាងលទ្ធភាពទិញស្បៀងអាហារនឹងភាពក្រីក្រ ឬរវាងវិបត្តិនៃការប្រែប្រួលអាកាសធាតុទៅនឹងផលជះលើអាហារូបត្ថម្ភ ដែលទាំងអស់នេះបានធ្វើឲ្យមានការផ្តោតតែទៅលើគោលនយោបាយដាច់ដោយឡែក ការបែងចែកធនធានមិនមានសក្តិសិទ្ធិភាព និងផលជះពីការវិនិយោគសាធារណៈថយចុះ។ ដូច្នេះការពង្រឹងប្រព័ន្ធតាមដានប្រព័ន្ធស្បៀងគឺមានសារៈសំខាន់ មិនត្រឹមតែសម្រាប់ការតាមដានវឌ្ឍនភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីឲ្យការសម្រេចចិត្តធ្វើឡើងប្រកបដោយសក្តិសិទ្ធិភាពផ្អែកលើភស្តុតាង មានការសម្របសម្រួលអន្តរៈវិស័យ និងមានគណនេយ្យភាព។

គំនិតផ្តួចផ្តើមរាប់ថយក្រោយសម្រាប់ប្រព័ន្ធស្បៀង (FSCI)

គំនិតផ្តួចផ្តើមរាប់ថយក្រោយសម្រាប់ប្រព័ន្ធស្បៀង (FSCI) មានដើមកំណើតពីកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងរបស់អង្គការសហប្រជាជាតិ និងជាកិច្ចសហការអន្តរៈជំនាញ ដែលឥឡូវនេះ មានអ្នកជំនាញលើប្រព័ន្ធស្បៀងជាង ៦៥ នាក់មកពីស្ថាប័នជាង១០ នៅទូទាំងពិភពលោក។ FSCI បានបង្កើតក្របខ័ណ្ឌសូចនាករតាមដានសកល ដែលគ្របដណ្តប់លើផ្នែកចំនួន ៥៖ (១) របបអាហារ អាហារូបត្ថម្ភ និងសុខភាព; (២) បរិស្ថាន ធនធានធម្មជាតិ និងផលិតកម្ម; (៣) ជីវភាពរស់នៅ ភាពក្រីក្រ និងសមធម៌; (៤) អភិបាលកិច្ច; និង (៥) ភាពធន់[9] ។ ផ្អែកតាមលទ្ធផលពីការពិគ្រោះយោបល់ ក្របខ័ណ្ឌសូចនាករសរុបចំនួន ៥០ ត្រូវបានកំណត់សម្រាប់ផ្នែកទាំង ៥ នេះ និងបង្កើតបានជាក្របខ័ណ្ឌសូចនាករតាមដានសកលមួយ ដើម្បីតាមដានវឌ្ឍនភាពនៃបរិវត្តកម្មប្រព័ន្ធស្បៀង។ FSCI បានបោះផ្សាយព័ត៌មានថ្មីៗ អំពីលទ្ធផលនៃការតាមដានប្រចាំឆ្នាំ រួមជាមួយការវិភាគតាមផ្នែកនិមួយៗ ដើម្បីវាយតម្លៃនិន្នាការសកល និងតម្រូវការសម្រាប់ការប្រែប្រួលណាមួយពាក់ព័ន្ធនឹងគោលនយោបាយនៅក្នុងប្រព័ន្ធស្បៀង។ ក្របខ័ណ្ឌសូចនាករសកលរបស់ FSCI ត្រូវបានកែសម្រួលឲ្យស្របតាមបរិបទប្រទេសកម្ពុជា ដើម្បីឆ្លុះបញ្ចាំងអំពីតម្រូវការអាទិភាព និងប្រព័ន្ធទិន្នន័យដែលមានស្រាប់ ហើយកម្ពុជាបានជ្រើសរើសចូលរួមក្នុងដំណើរការនេះ ដោយសារការកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹងអភិបាលកិច្ចប្រព័ន្ធស្បៀងដែលផ្អែកលើភស្តុតាង។

ក្របខណ្ឌសូចនាករតាមដានរបស់ FSCI គួរតែត្រូវបានយល់ថា ជាក្របខណ្ឌគាំទ្របន្ថែមមួយ ជាជាងត្រូវបានចាត់ទុកថាជាប្រព័ន្ធតាមដានមួយផ្សេងទៀតសម្រាប់កម្ពុជា។ គុណតម្លៃនៃក្របខណ្ឌសូចនាករតាមដាននេះ ស្ថិតនៅលើការពង្រឹងរចនា សម្ព័ន្ធនៃប្រព័ន្ធតាមដានដែលមានស្រាប់របស់កម្ពុជា និងការបន្សាំការងារ រៀបចំរបាយការណ៍នៅកម្រិតប្រទេស និងសម្រាប់រាយការណ៍អំពីវឌ្ឍនភាពនៃការប្តេជ្ញាចិត្តរបស់កម្ពុជានៅកម្រិតសកល។ នៅពេលអនុវត្តប្រកបដោយប្រសិទ្ធភាព ក្របខណ្ឌ សូចនាករតាមដានរបស់ FSCI អាចគាំទ្រដល់ការអនុវត្តផែនការសកម្មភាពជាយុទ្ធសាស្ត្រផ្សេងៗ បន្សាំការងាររៀបចំរបាយការណ៍ និងពង្រឹងភាពស៊ីសង្វាក់គ្នារវាងវិស័យផ្សេងៗ នៅតាមក្រសួង ស្ថាប័ន និងក្នុងចំណោមដៃគូនានា។ កិច្ចការនេះក៏អាចធានាបានថា កម្ពុជាមានភាពម្ចាស់ការទៅលើការងារតាមដាន ខណៈជាមួយគ្នា ក៏រំលេចចេញនូវភាពដែលអាចប្រៀបធៀបគ្នាបាន និងភាពត្រឹមត្រូវនៃវិធីសាស្ត្រសម្រាប់តាមដានដែលបានប្រើប្រាស់នៅកម្រិតសាកលផងដែរ។ កម្ពុជាស្ថិតក្នុងស្ថានភាពសមស្របមួយ ដើម្បីអភិវឌ្ឍក្របខណ្ឌសូចនាករតាមដានប្រព័ន្ធស្បៀងដ៏រឹងមាំមួយដោយហេតុថា ការធ្វើអង្កេតនានា និងសំណុំទិន្នន័យដែលមានគុណភាពខ្ពស់របស់ខ្លួនបានផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កិច្ចការនេះ។ ប្រព័ន្ធរដ្ឋបាលនៅតាមក្រសួងស្ថាប័ន រួមជាមួយប្រព័ន្ធមូលដ្ឋានទិន្នន័យភូមិឃុំ (CDB) ក៏បានផ្តល់នូវច្រកផ្លូវមួយ ដើម្បីតភ្ជាប់សូចនាករថ្នាក់ជាតិជាមួយការធ្វើផែនការថ្នាក់ក្រោមជាតិ។ ចំណុចមានប្រៀបមួយផ្សេងទៀតរបស់កម្ពុជា គឺសមត្ថភាពរបស់ខ្លួនក្នុងការភ្ជាប់ទិន្នន័យថ្នាក់ជាតិជាមួយទិន្នន័យវិសមភាពនៅថ្នាក់ខេត្ត និងការធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតឃុំ ដែលទាំងអស់នេះ ត្រូវបានគាំទ្រដោយយន្តការសម្របសម្រួលដែលបានបង្កើតឡើងដោយ CARD ។ ដូច្នេះ បញ្ហាប្រឈមដែលមានគឺមិនមែនជាភាពអាចរកបាននៃទិន្នន័យយកមកប្រើនោះទេ ប៉ុន្តែគឺជាការធ្វើសមាហរណកម្ម ការចាត់អាទិភាព និងការប្រើប្រាស់ទិន្នន័យប្រកបដោយសក្តិសិទ្ធិភាពសម្រាប់ការងារគោលនយោបាយ និងការងារផែនការ ។

សូចនាករតាមដានអាទិភាព

ការជ្រើសរើសសូចនាករតាមដានចាប់ផ្តើមពីការសិក្សាលើឯកសារស្តីពីយុទ្ធសាស្ត្រជាតិតាមវិស័យ និងពហុវិស័យរបស់កម្ពុជា[10] ដែលពាក់ព័ន្ធប្រព័ន្ធស្បៀង រួមជាមួយឯកសារផ្សេងទៀតទាក់ទងនឹងការប្តេជ្ញាចិត្តជាសកលរបស់កម្ពុជាក្រោមគំនិតផ្តួចផ្តើមសកល និងតំបន់នានា រួមមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅ

7. National Institute of Statistics, Ministry of Health and ICF (2022) Cambodia Demographic and Health Survey 2021–22. Phnom Penh and Rockville, MD
8. World Food Programme. (2023). Cambodia Country Brief. Rome: World Food Programme.
9. GAIN, The Columbia Climate School, Cornell University, and FAO (2026), The Food Systems Countdown Initiative. Viewed at: https://www.foodcountdown.org/indicator-architecture
10. Including the Royal Government of Cambodia's Second Roadmap for Food Systems for Sustainable Development 2025–2030 and the Third National Strategy for Food Security and Nutrition (NSFSN) 2024–2028.

កម្ពុជា (CSDGs) ការប្តេជ្ញាចិត្តស្តីពីអាហារូបត្ថម្ភសម្រាប់កំណើន (N4G) ផែនការជាតិរួមចំណែកឆ្លើយ តបការប្រែប្រួលអាកាសធាតុ កម្ពុជា ដំណាក់កាលទី៣ (NDC3.0) និង ឯកសារសម្ព័ន្ធជើងឯក បរិវត្តកម្មប្រព័ន្ធស្បៀង (ACF) ដោយមានគោលបំណងបង្កើតក្របខណ្ឌសូចនាករួមមួយដែលសមស្របនឹងតម្រូវការតាមដាន ពង្រឹងភាពស៊ីសង្វាក់គ្នានៅតាមក្រសួងស្ថាប័ន និងធ្វើឲ្យដំណើរការរាយការណ៍មានភាពសាមញ្ញ ខណៈពេលជាមួយគ្នា ក៏ដើម្បីជាប្រយោជន៍នៃសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។

ការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធនៅខែកុម្ភៈ ឆ្នាំ ២០២៦ ទទួលបានការយល់ស្របជារួមមួយទៅលើក្របខណ្ឌសូចនាករតាមដាន អាទិភាពដែលស្របគ្នាទៅនឹងក្របខណ្ឌគោលនយោបាយ និងប្រព័ន្ធទិន្នន័យរបស់កម្ពុជា ក៏ដូចជាក្របខណ្ឌសូចនាករសកលរបស់ FSCI ។ សិក្ខាសាលានេះបានអញ្ជើញតួអង្គពាក់ព័ន្ធមកពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ គ្រឹះស្ថានសិក្សាស្រាវជ្រាវ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីធ្វើការកំណត់យកសូចនាករអាទិភាពសម្រាប់កម្ពុជា ដែលគ្របដណ្តប់លើផ្នែកទាំង ៥ របស់ FSCI។ អ្នកពាក់ព័ន្ធបានពិនិត្យមើលសូចនាករ និងទិន្នន័យដែលមានស្រាប់ ដោយផ្តោតសំខាន់លើភាពស្របទៅនឹងទិសដៅគោលនយោបាយរបស់សូចនាករ ភាពត្រឹមត្រូវនៃវិធីសាស្ត្រដែលយកមកប្រើប្រាស់ ភាពដែលអាចអនុវត្តបាន និងដែនគ្របដណ្តប់នៃសូចនាករនិមួយៗ។

នៅក្នុងផ្នែក "**របបអាហារ អាហារូបត្ថម្ភ និងសុខភាព**" អ្នកពាក់ព័ន្ធបានផ្តល់អនុសាសន៍ជ្រើសរើសសូចនាករអាទិភាព ដែលរួមមាន ពិន្ទុភាពចម្រុះនៃរបបអាហារ និងការបរិភោគអាហារប៉ះពាល់សុខភាពក្នុងចំណោមមនុស្សមកពីក្រមអាយុផ្សេងគ្នា។ អ្នកពាក់ព័ន្ធបានសង្កត់ធ្ងន់លើតម្រូវការឲ្យមានសូចនាករទាក់ទងនឹងការផ្តល់អាហារតាមសាលារៀន ការទទួលបានទឹកស្អាត ការប្រើប្រាស់អំបិលអ៊ីយ៉ូដ និងការរាស់វែងអសន្តិសុខស្បៀង ដោយប្រើវិធីសាស្ត្រវាស់វែងទៅលើកម្រិតនៃបទពិសោធន៍ជួបប្រទះអសន្តិសុខស្បៀង ឬ FIES និងការគណនា "ពិន្ទុនៃការបរិភោគអាហារ" ។ សូចនាករទាក់ទងនឹងអាហារូបត្ថម្ភសំខាន់ៗ ហើយដែលស្របតាមក្របខណ្ឌសកលនៃ FSCI រួមមាន ភាពចម្រុះនៃរបបអាហារអប្បបរមាសម្រាប់ស្ត្រី និងកុមារ លទ្ធភាពទិញរបបអាហារដែលមានសុខភាពល្អ និងការហូបអាហារដែលប៉ះពាល់ដល់សុខភាព។

សម្រាប់ផ្នែកស្តីពី "**បរិស្ថាន ធនធានធម្មជាតិ និងផលិតកម្ម**" ក៏មានសូចនាករមួយចំនួនត្រូវបានចាត់ជាអាទិភាព ដោយអ្នកចូលរួមបានសង្កត់ធ្ងន់លើការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុតាមរយៈការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការអនុវត្តការផលិតប្រកបដោយចីរភាព និងឆ្លាតវៃចំពោះអាកាសធាតុ និងរង្វាស់ទំហំផលិតកម្មសម្រាប់ជាអាហារ។ សូចនាករដែលបានស្នើឡើងរួមមាន តម្លៃបន្ថែមលើផលិតកម្មកសិកម្ម



Photo: © Wosunan/Envato

និងការគ្រប់គ្រងធនធានដីប្រកបដោយចីរភាព។ អ្នកពាក់ព័ន្ធក៏បានបញ្ជាក់ពីសារៈសំខាន់ទៅលើទំហំគ្របដណ្តប់របស់ប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ថាមពលប្រកបដោយចីរភាពសម្រាប់ការងារកសិដ្ឋាន ការធ្វើពិពិធកម្មដំណាំ និងវិធានការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជាទំហំនៃគម្របព្រៃឈើ និងតំបន់ការពារទេសភាព។ ទំហំនៃវារីវប្បកម្មនិងនេសាទ ព្រមទាំងការបាត់បង់និងកាកសំណល់អាហារក៏ត្រូវបានបញ្ចូលទៅក្នុងសំណុំសូចនាករផងដែរ បើទោះបីជាមិនទាន់មានប្រភពទិន្នន័យស្តីអំពីបរិមាណកាកសំណល់អាហារក៏ដោយ។

សម្រាប់ផ្នែក "**ជីវភាពរស់នៅ ភាពក្រីក្រ និងសមធម៌**" អ្នកពាក់ព័ន្ធបានចាត់អាទិភាពលើសូចនាករដែលវាស់វែងអត្រាមានការងារក្នុងវិស័យកសិកម្ម ប្រាក់ចំណូលពីកសិកម្ម ផលិតភាពកម្លាំងពលកម្ម ទំហំនៃការគ្របដណ្តប់សេវាគាំពារសង្គម និងកម្មសិទ្ធិដីធ្លី បែងចែកតាមភេទ។ សូចនាករសំខាន់ៗទាំងនោះរួមមាន ការចូលរួមរបស់ស្ត្រីនិងយុវជនក្នុងសហគមន៍កសិកម្មនិងសហគ្រិនភាព អត្រាការងារ និងសហគ្រាសធុនតូចនិងមធ្យមដែលពាក់ព័ន្ធការកែច្នៃម្ហូបអាហារ និងចំនួនកសិករខ្នាតតូចក្នុងសហគមន៍កសិកម្មទំនើប។

នៅក្នុងផ្នែក "**អភិបាលកិច្ច**" អ្នកពាក់ព័ន្ធបានផ្តោតលើប្រភេទសូចនាករទាក់ទងនឹងស្ត្រីក្នុងអភិបាលកិច្ចមូលដ្ឋាន ការចូលរួមពីវិស័យឯកជន ដំណើរការនៃវេទិកាពហុវិស័យសម្រាប់អភិបាលកិច្ចប្រព័ន្ធស្បៀង ការដាក់បញ្ចូលសកម្មភាពទាក់ទងនឹងសន្តិសុខស្បៀងនិងប្រព័ន្ធស្បៀងទៅក្នុងផែនការឃុំ ការធ្វើអធិការកិច្ចសុវត្ថិភាពចំណីអាហារ និងវត្តមាននៃផែនការសកម្មភាពអាកាសធាតុ។

ក្រោមផ្នែកស្តីពី "**ភាពធន់**" អ្នកចូលរួមបានផ្តល់អនុសាសន៍ឲ្យដាក់បញ្ចូលសូចនាករទាក់ទងនឹងតំបន់ដីដាំដុះដែលរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួតនិងទឹកជំនន់ ឃុំដែលមានផែនការគ្រប់គ្រងគ្រោះមហន្តរាយដែលបានធ្វើបច្ចុប្បន្នភាព កម្រិតនៃការប្រឈមនឹងហានិភ័យអាកាសធាតុក្នុងគ្រួសារ ការទទួលបានទីផ្សារនិងភាពមិនប្រក្រតីនៃតម្លៃស្បៀងអាហារ គ្រួសារដែលប្រើប្រាស់យុទ្ធសាស្ត្រទប់ទល់នឹងវិបត្តិ និងកម្រិតនៃស្បៀងបម្រុងក្នុងស្រុក។ អ្នកចូលរួមក៏បានផ្តល់អនុសាសន៍ឱ្យដាក់បញ្ចូលប្រព័ន្ធព្រមានជាមុន ភ្នាក់ងារផ្សព្វផ្សាយដែលបានបណ្តុះបណ្តាលអំពីភាពធន់នឹងគ្រោះមហន្តរាយ ទំហំនៃការផ្តល់ថវិកាគាំពារសង្គមដែលឆ្លើយតបនឹងវិបត្តិ និងភាគរយនៃភូមិដែលមានលទ្ធភាពទទួលបានទឹកប្រើប្រាស់ក្នុងគ្រាអាសន្ន។

ការរៀបចំសូចនាករទាំងនេះបានរួមគ្នាផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការតាមដានបរិវត្តកម្មប្រព័ន្ធស្បៀង។ ទោះជាយ៉ាងណាក៏ដោយ ប្រសិទ្ធភាពនៃការតាមដានគឺអាស្រ័យលើសមត្ថភាពក្នុងការធ្វើសមាហរណកម្មទិន្នន័យនៅតាមវិស័យពាក់ព័ន្ធ និងតភ្ជាប់ការតាមដានទៅនឹងសកម្មភាពគោលនយោបាយ (policy actions)។

ភាពអាចរកបាននៃទិន្នន័យ និងគម្លាតនៃទិន្នន័យ

ទោះបីជាមានមូលដ្ឋានគ្រឹះរឹងមាំក៏ដោយ ក៏នៅមានគម្លាតនៃទិន្នន័យមួយចំនួនបានរឹតត្បិតដល់កិច្ចការតាមដានឲ្យទទួលបានសំក្ខសិទ្ធភាព រួមមាន កង្វះព័ត៌មានទាក់ទងនឹងបរិយាកាសអាហារ រួមទាំងលទ្ធភាពទិញ ការទទួលបាននិងការទទួលទានអាហារដែលមានសុខភាពល្អធៀបនឹងអាហារដែលប៉ះពាល់ដល់សុខភាព។ ការណ៍នេះបានរឹតត្បិតលទ្ធភាពក្នុងការតាមដានការផ្លាស់ប្តូររបបអាហារ និងដោះស្រាយបញ្ហានៃការកើនឡើងនៃជំងឺមិនឆ្លង ដែលបង្កើតបានជាចន្លោះនៃភាពងងឹតដ៏សំខាន់មួយ (blind spot) ដើម្បីស្វែងយល់ថាតើប្រព័ន្ធស្បៀងត្រូវធ្វើយ៉ាងណាឲ្យមានផលជះលើផ្នែកអាហារូបត្ថម្ភ។ បើក្រឡេកមើលទៅលើ ផ្នែកខាងលើនៃវដ្តទិន្នន័យ (upstream) ក៏នៅមានភាពទន់ខ្សោយនៃទិន្នន័យជាពិសេសគឺនៅចំកណ្តាលនៃខ្សែច្រវាក់តម្លៃ រួមមានការកែច្នៃអាហារ ការស្តុកទុក ការចែកចាយ និងទីផ្សារ។ ការណ៍នេះបានរឹតត្បិតដល់ការស្វែងយល់អំពីការប្រែប្រួលនៃតម្លៃសេដ្ឋកិច្ចនៅក្នុងប្រព័ន្ធស្បៀងទាំងមូល។ ទិន្នន័យដែលបែងចែកតាមភេទសម្រាប់ខ្សែច្រវាក់តម្លៃគឺខ្វះខាតជាពិសេសផងដែរ។ បើគ្មានព័ត៌មានទាំងនេះទេ នឹងធ្វើឲ្យមានការពិបាកក្នុងការវាយតម្លៃថាតើ ខ្សែច្រវាក់តម្លៃរួមចំណែកដល់ការបង្កើតប្រាក់ចំណូល ភាពអាចរកបាននៃអាហារ និងភាពធន់ តាមរបៀបណា -- និងសម្រាប់អ្នកណា។

កង្វះខាតទិន្នន័យក៏មាននៅក្នុងផ្នែកអាកាសធាតុនិងធនធានធម្មជាតិ ដោយមានគម្លាតនៅលើទិន្នន័យទាក់ទងនឹង សុខភាពដី គុណភាពទឹក ជីវៈចម្រុះ និងការបំភាយឧស្ម័នពីការងារកសិកម្ម។ ចន្លោះប្រហោងទាំងនេះរារាំងលទ្ធភាពរបស់កម្ពុជាក្នុងការបន្សីការតាមដានប្រព័ន្ធស្បៀងសម្រាប់ NDC 3.0 និងការប្តេជ្ញាចិត្តផ្នែកអាកាសធាតុជារួម[11]។ លើសពីនេះ ទិន្នន័យមិនគ្រប់គ្រាន់អាចរឹតត្បិតដល់ការទទួលបានហិរញ្ញប្បទានអាកាសធាតុ (ឧទាហរណ៍. ការមិនអាចបង្ហាញបានអំពីកម្រិតនៃផលជះដែលទទួលបាន) និងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីតាមដានលទ្ធផលនៃការកាត់បន្ថយ និងការសម្របខ្លួនផ្នែកអាកាសធាតុ ។ លើសពីនេះក៏នៅមានកង្វះខាតលើការវាស់វែងជាប្រចាំទៅលើប្រសិទ្ធភាពនៃអភិបាលកិច្ច និងកម្រិតនៃការអនុវត្ត រួមជាមួយកង្វះខាតនៃការវាស់វែងជាប្រចាំ ទៅលើលទ្ធផលនៃការអនុវត្តកម្មវិធី លទ្ធផលសមិទ្ធកម្មនៃស្ថាប័ន និងកម្រិតគណនេយ្យភាពនៅតាមវិស័យពាក់ព័ន្ធ ។ ប្រសិនបើគ្មានសូចនាករបែបនេះទេ នឹងមានភាពលំបាកក្នុងការវាយតម្លៃថាតើ គោលនយោបាយកំពុងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពកម្រិតណា ឬពិបាកស្វែងរកឲ្យឃើញថា តើផ្នែកណាមួយដែលត្រូវការសកម្មភាពកែតម្រូវឬអត់។

នៅកិច្ចពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធបានបញ្ជាក់ថា ឧបសគ្គចម្បងនៅកម្ពុជាមិនមែនជាការខ្វះខាតទិន្នន័យទេ ប៉ុន្តែជាការខ្វះខាតទៅលើយន្តការអភិបាលកិច្ចផ្លូវការមួយសម្រាប់ចែករំលែកទិន្នន័យ ការធ្វើសមាហរណកម្ម និងការប្រើប្រាស់ទិន្នន័យទាំងនោះ។ ប្រព័ន្ធទិន្នន័យដែលបែកខ្ញែកនឹងរារាំងដល់ការវិភាគអំពីរបៀបដែលអន្តរាគមន៍ក្នុងវិស័យកសិកម្ម ទីផ្សារ និងសេវាគាំពារសង្គមមានអន្តរកម្មរវាងគ្នានឹងគ្នា ដែលស្ថានភាពនេះនឹងបង្កើតឲ្យមានគោលនយោបាយដាច់ដោយឡែក និងរារាំងដល់ប្រសិទ្ធភាពនៃការវិនិយោគសាធារណៈ។ ប្រសិនបើយើងដាក់បញ្ចូលគ្នា គម្លាតទិន្នន័យទាំងនេះនឹងរារាំងដល់ពីការតភ្ជាប់គ្នារវាងលទ្ធផលចុងក្រោយនៃផលិតកម្ម ទីផ្សារ របបអាហារ និងផលជះទៅលើសុខភាព ដែលធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ស្នូលនៃបរិវត្តកម្មប្រព័ន្ធស្បៀង និងរឹតត្បិតដល់ប្រសិទ្ធភាពនៃការវិនិយោគសាធារណៈ។

11. UNFCCC/National Council for Sustainable Development. (2025). Nationally Determined Contribution (NDC 3.0). Phnom Penh

អនុសាសន៍សម្រាប់ពង្រឹងការតភ្ជាប់រវាងគោលនយោបាយនិងការងារតាមដាន

១. **បង្កើតរចនាសម្ព័ន្ធប្រព័ន្ធតាមដានជាតិមួយសម្រាប់ប្រព័ន្ធស្បៀង៖** បង្កើតប្រព័ន្ធតាមដានរួមមួយដែលដឹកនាំដោយ CARD និងតភ្ជាប់ជាមួយវិទ្យាស្ថានជាតិស្ថិតិ រួមជាមួយការកំណត់ច្បាស់លាស់អំពីតួនាទីក្រសួងស្ថាប័នពាក់ព័ន្ធ។ យន្តការនេះនឹងធ្វើឲ្យការសម្របសម្រួលមានលក្ខណៈផ្លូវការ ធានាបាននូវស្តង់ដារទិន្នន័យ (data standardization) និងការបន្សុីការតាមដាននៅក្នុងយុទ្ធសាស្ត្រជាតិ និងការប្តេជ្ញាចិត្តរបស់កម្ពុជានៅអន្តរជាតិ។ ការ អនុម័ត្តជាផ្លូវការ និងការកំណត់អាណត្តិការងាររបស់ក្រសួងស្ថាប័នពាក់ព័ន្ធគឺមានសារៈសំខាន់ ដើម្បីធ្វើឲ្យការងាររួមបញ្ចូលទិន្នន័យឆ្លងវិស័យអាចដំណើរការបាន ជាពិសេសកន្លែងដែលសូចនាករគ្របដណ្តប់លើការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នច្រើន។ ប្រព័ន្ធតាមដានដែលរឹងមាំក៏នឹងគាំទ្រដល់លទ្ធភាពរបស់កម្ពុជាក្នុងការទទួលបាន និងគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ និងការអភិវឌ្ឍ តាមរយៈការកែលម្អតម្លាភាព គណនេយ្យភាព និងការវាស់វែងលទ្ធផលទៅលើការបន្សុំ និងភាពធន់។

២. **បញ្ចូលការតាមដានទៅក្នុងដំណើរការធ្វើផែនការ៖** បញ្ចូលសូចនាករអាទិភាពនៅក្នុងដំណើរការធ្វើផែនការជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីវិនិយោគឃុំសង្កាត់ និងផែនការអភិវឌ្ឍន៍ឃុំសង្កាត់។

៣. **បញ្ចូលការងារតាមដានទៅក្នុងប្រព័ន្ធថវិកា៖** ភ្ជាប់លទ្ធផលនៃការងារតាមដានទៅនឹងការបែងចែកថវិកា និងការរៀបចំកម្មវិធីផ្សេងៗ ដើម្បីធានាថាទិន្នន័យត្រូវបានប្រើប្រាស់ដោយផ្ទាល់សម្រាប់គាំទ្រដល់ការសម្រេចចិត្តផ្នែកគោលនយោបាយ។

៤. **បង្កើតផ្ទាំងគ្រប់គ្រងព័ត៌មានតាមដាន** (dashboard) **ជាមួយនឹងយន្តការទទួលខុសត្រូវ៖** បង្កើតនិងថែទាំផ្ទាំងគ្រប់គ្រងព័ត៌មានដែលអាចចូលមើលបានជាសាធារណៈ ដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ និងតាមដានវឌ្ឍនភាពទល់នឹងសូចនាករសំខាន់ៗ និងការប្តេជ្ញាចិត្តទាំងឡាយរបស់កម្ពុជា។ ប្រព័ន្ធនេះគួរតែរួមបញ្ចូលយន្តការគណនេយ្យភាព (accountability triggers) ដែលទាមទារឲ្យក្រសួងស្ថាប័នពាក់ព័ន្ធពិនិត្យឡើងវិញនូវសូចនាករដែលមិនមានដំណើរការល្អ និងលើកសំណើរអំពីសកម្មភាពសម្រាប់កែលម្អ។ការរាយការណ៍ជាសាធារណៈនិងជាប្រចាំ អាចពង្រឹងគណនេយ្យភាពរបស់ក្រសួងស្ថាប័ន និងលើកទឹកចិត្តឲ្យមានការឆ្លើយតបគោលនយោបាយទាន់ពេលវេលាជាងមុន សម្រាប់សូចនាករណាដែលបង្ហាញលទ្ធផលមិនល្អ។

៥. **ប្រើប្រាស់វិធីសាស្ត្រពង្រឹងប្រព័ន្ធទិន្នន័យដែលជំរុញដោយគោលនយោបាយនិងការជាក់ឲ្យអនុវត្តជាដំណាក់កាល៖** ចាប់ផ្តើមជាមួយនឹងសំណុំសូចនាករស្នូល ដែលត្រូវបានគាំទ្រដោយប្រព័ន្ធទិន្នន័យដែលមានស្រាប់ ដើម្បីជំរុញឱ្យមានប្រតិបត្តិការបានឆាប់។ ការជ្រើសរើសសូចនាករត្រូវតែថ្លឹងថ្លែងរវាងភាពរឹងមាំនៃវិធីសាស្ត្រដែលប្រើជាមួយនឹងលទ្ធភាពរបស់ក្រសួង ស្ថាប័ន ដោយផ្តល់អាទិភាពដល់សូចនាករដែលពាក់ព័ន្ធនឹងទិសដៅគោលនយោបាយ និងត្រូវបានប្រើសម្រាប់ធ្វើការរាយការណ៍នៅក្នុងប្រព័ន្ធដែលមានស្រាប់។ ទន្ទឹមនេះ ត្រូវធ្វើការវិនិយោគលើការបិទគម្លាតទិន្នន័យសំខាន់ៗ ជាពិសេសទិន្នន័យទាក់ទងនឹងបរិស្ថានស្បៀង ខ្សែច្រវាក់តម្លៃ ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ច ស្របតាមអាទិភាពជាតិ និងឱកាសហិរញ្ញប្បទាន រួមទាំង NDC 3.0។